**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៦.សសរ

## សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ**

**ចំពោះគំរោងអភិវឌ្ឍន៍កោះកោងកាងរបស់ក្រុមហ៊ុន កោះកោងកាង អភិវឌ្ឍន៍ គ្រុប**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ៨៨អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា។
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧។
- អនុលោមតាម តំរូវការចាំបាច់

## សម្រេច

**ប្រការ១:** បង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងអភិវឌ្ឍន៍*កោះកោងកាង* ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងជាអនុប្រធាន "ក.អ.ក" | ប្រធាន |
| ២- | ឯកឧត្តម គង់ ទិបុល | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន "ក.អ.ក" | អនុប្រធាន |
| ៣- | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- | ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | ឯកឧត្តម សួន សិទ្ធី | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម សេង លឹមនៅ | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | ឯកឧត្តម រស់ រ៉ែន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- | ឯកឧត្តម ប្រាជ្ញ ស៊ុន | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- | ឯកឧត្តម អ៊ិត ណារ្វ៉ី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០- | ឯកឧត្តម អ៊ុក ចាន់ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១- | ឯកឧត្តម ឌុច ចនឆ័ត្រ | អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២- | ឯកឧត្តម សាយ ហាក់ | អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ១៣- | លោក អន សុផារណារ៉ា | ប្រធាននាយកដ្ឋាន នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៤- | លោក ពន ណារិន | ប្រធាននាយកដ្ឋាន នៃគណៈកម្មាធិការវិនិយោគកម្ពុជា | លេខាធិការ |

សមាជិកក្រុមការងារទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំអោយបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** ក្រុមការងារដូចមានចែងក្នុងប្រការ១ ខាងលើ មានភារកិច្ចដូចខាងក្រោម :

- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង ដើម្បីមានមូលដ្ឋានក្នុងការពិនិត្យពិចារណាលើបណ្តឹង-របាយការណ៍ស្តីពីហេតុប៉ះពាល់បរិស្ថាន ដែលផ្តល់ដោយសាមីក្រុមហ៊ុន និងសិក្សាពីផលប្រយោជន៍សេដ្ឋកិច្ច សំដៅជំរុញដោះស្រាយការងារអភិវឌ្ឍន៍*កោះកោងកាង* អោយបានឆាប់ ។
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តន៍ការងាររបស់ក្រុមហ៊ុន តាមជំហាននីមួយៗ ដែលមានចែងក្នុងអនុស្សារណៈ ។
- ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពការងារ និងពីទិសដៅត្រូវអនុវត្តបន្ត ជូនប្រមុខរាជរដ្ឋាភិបាល ។
- លើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ៣:** ក្រុមការងារនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងកិច្ចដំណើរការរបស់ខ្លួន ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រី ក្រសួងបរិស្ថាន-ប្រធាន "ក.អ.ក"-រដ្ឋមន្ត្រីគ្រប់

ក្រសួង-ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ